ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....៤០៦...សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រង តែមប្រើនិដ្ឋាការ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល-ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យ របស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការរៀបចំសេចក្តី-ព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៦
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញសារាចររបស់រាជរដ្ឋាភិបាល លេខ ០៦ សរ ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសស្តីពីការប្រមូលចំណូលទិដ្ឋាការលេខ ៣០៤ សហវ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០១
- បានឃើញចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០១ លើលិខិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៥៤១៨ សហវ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០១
- បានឃើញប្រកាសលេខ ៨៦១ សហវ.ថហ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីវិធានការគ្រប់គ្រងតែមប្រ៊ីទិដ្ឋាការស្អិត
- យោងស្មារតីនៃការប្រជុំអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ធនាគារជាតិនៃកម្ពុជា ស្តីពីយន្តការគ្រប់គ្រង តែមប្រ៊ីទិដ្ឋាការនាថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦
- តាមការចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីតែមប្រ៊ីទិដ្ឋាការ

សំរេច

**ប្រការ១ :** តែមប្រ៊ីទិដ្ឋាការ ត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ២ :** ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៦ តែមប្រ៊ីទិដ្ឋាការស្អិតមានពីរប្រភេទ គឺ :

<u>ប្រភេទទី ១</u> : មានផ្ទៃពណ៌បៃតងស្រស់សំរាប់ផ្តល់ឱ្យជនបរទេសធ្វើដំណើរចូលមកប្រទេសកម្ពុជា ដែលរំលេចដោយអក្សរឡាតាំងធំៗ A,B,C,D,E,T និង K ដែលជាកំណត់សំគាល់នៃប្រភេទតែមប្រ៊ីទិដ្ឋាការនិមួយៗ ស្របតាមមាត្រា ៤ នៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីបែបបទសំរាប់អនុវត្ត ចំពោះការអនុវត្តឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល-ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ។

<u>ប្រភេទទី ២</u> : មានផ្ទៃពណ៌ខៀវថ្លា ដែលមានអក្សរ EX នៅក្នុងផ្ទៃ សំរាប់ពន្យារទិដ្ឋាការការស្នាក់នៅក្នុងប្រទេសកម្ពុជា លើកលែងតែអក្សរ K ចេញ ។

**ប្រការ៣ :** តែមប្រ៊ីទិដ្ឋាការត្រូវតែមល់ទុកនៅរតនាគារជាតិ ។ រតនាគារជាតិត្រូវធ្វើបញ្ជីសារពើភ័ណ្ឌតែមប្រ៊ីទិដ្ឋាការរៀងរាល់ត្រីមាស ដោយមានការចូលរួមពីនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ។ ដោយឡែកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ តែមប្រ៊ីទិដ្ឋាការរៀងរាល់ មុនដំណាច់ត្រីមាសផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នា.ចំណូលមិនមែនសារពើពន្ធ) ។ នាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធ ត្រូវថតចម្លងមួយច្បាប់ផ្ញើជូនរតនាគារជាតិ ។

**ប្រការ៤ :** តែមប្រ៊ីទិដ្ឋាការត្រូវបានបោះពុម្ពបន្ថែម តាមសំណើរបស់ប្រធានរតនាគារជាតិ ក្រោយពេលពិនិត្យឃើញថាមានតម្រូវការចាំបាច់ក្នុងការបោះពុម្ព និងបានពិភាក្សាឯកភាពគ្នាជាមួយ នឹងនាយកដ្ឋាន ចំណូលមិនមែន-សារពើពន្ធ ព្រមទាំងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ក្រសួងមហាផ្ទៃ ។ យន្តការនៃការបោះពុម្ព និងបញ្ចូលឃ្លាំង នូវតែមប្រ៊ីទិដ្ឋាការ ត្រូវកំណត់ដោយគណៈកម្មការមួយដែលនឹងត្រូវបង្កើតឡើង ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៥ :** រតនាគារជាតិត្រូវបញ្ចេញតែមប្រិ៍ទិដ្ឋាការ បន្ទាប់ពីមានសំណូមពររបស់អង្គភាពមានសមត្ថកិច្ច នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ក្រោយពីបានឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយត្រូវផ្ញើឯកសារច្បាប់ចម្លងទាំងនេះ មកនាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធមួយច្បាប់ ។

**ប្រការ៦ :** ចំណូលពីតែមប្រិ៍ទិដ្ឋាការដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ប្រមូលបានត្រូវបង់ចូលថវិការដ្ឋត្រង់ទៅគណនីប្រាក់បញ្ញើចំណូលជារូបិយប័ណ្ណ ដុល្លាអាមេរិក បណ្តោះ-អាសន្នរបស់សាមីក្រសួងនីមួយៗ នៅធនាគារជាតិនៃកម្ពុជា។ ក្រសួងសាមី ត្រូវសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបើកគណនីប្រាក់បញ្ញើបណ្តោះអាសន្ននេះ នៅធនាគារជាតិនៃកម្ពុជា ។

ទឹកប្រាក់ដែលបានកត់ត្រាបញ្ចូលក្នុងគណនីបណ្តោះអាសន្ន មិនអាចដកយកទៅប្រើប្រាស់វិញបានទេ ។ ធនាគារជាតិ ត្រូវផ្ទេរដោយស្វ័យប្រវត្តិនូវសមតុល្យរបស់គណនីខាងលើទាំងនេះ ទៅគណនីលេខ ០១០២-៣៥.១២១១-T០២៣ របស់រតនាគារជាតិនៅរៀងរាល់ចុងថ្ងៃនីមួយៗ ហើយត្រូវជូនដំណឹងទៅសាមីក្រសួង ។ ក្រោយពីបានទទួលដំណឹងពីធនាគារជាតិនៃកម្ពុជា សាមីក្រសួងត្រូវផ្ញើសលាកប័ត្រចំណូលជាបន្ទាន់ទៅរតនាគារជាតិ ។

**ប្រការ៧ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ប្រធានរតនាគារជាតិ ព្រមទាំងប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៦

គាត ឈន់

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាពត៌មាន"
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធនាគារជាតិនៃកម្ពុជា
  "ដើម្បីសហការអនុវត្តន៍"
- ឯកសារ និង កាលប្បវត្តិ